# ក្រុមហ៊ុនផែស្ងួតបុកសេងភីភីអេសអ៊ីហ្សេតបើកសម្ពោធជាផ្លូវការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស



*លោកចម ប្រសិទ្ធ ក្នុងពិធីសម្ពោធជាផ្លូវការក្រុមហ៊ុនផែស្ងួតបុកសេងភីភីអេសអ៊ីហ្សេត*

ភ្នំពេញ: ក្រុមហ៊ុនផែស្ងួតបុកសេង ភីភីអេសអ៊ីហ្សេត (Bok Seng PPSEZ) ដែលមានទីតាំងស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញនោះ បានបើកសម្ពោធជាផ្លូវការហើយកាលពីរសៀលថ្ងៃទី១៦ខែតុលាឆ្នាំ២០០៨កន្លងមក ក្រោមអធិបតីភាពលោកចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងលោកស្រី ។

លោកស្រីឌុកញ៉ាលីម ឈីវហួរ អគ្គនាយកតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ បានមានប្រសាសន៍ឱ្យដឹងថា ក្រុមហ៊ុនផែស្ងួត Bok Seng PPSEZ គឺជាសមិទ្ធផលថ្មីមួយទៀតដែលបានបោះទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ។ ក្រុមហ៊ុននេះ ជាក្រុមហ៊ុនដែលដាក់ទុនវិនិយោគដោយក្រុមហ៊ុនដឹកជញ្ជូនមួយនៅប្រទេសសិង្ហបុរី ។ លោកស្រីឌុកញ៉ាលីម ឈីវហួរ បានបញ្ជាក់ឱ្យដឹងទៀតថា ផែស្ងួត Bok Seng PPSEZ ចាប់ដំណើរការជាផ្លូវការ និងទទួលបានជាអាទិភាពនូវកិច្ចសហប្រតិបត្តិការសេវាកម្មអាជីវកម្មផែស្ងួត ដោយផ្តោតទៅលើសេវាកម្មដឹកជញ្ជូនដែលមានកាតព្វកិច្ចពីរដាច់ដោយឡែកពីគ្នា គឺកាតព្វកិច្ចសេវាកម្មក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងកាតព្វកិច្ចសេវាកម្មក្រៅតំបន់ ។

លោកង ឿនស៊ួន អគ្គនាយកក្រុមហ៊ុនផែស្ងួតបុកសេងភីភីអេសអ៊ីហ្សេត ក៏បានមានប្រសាសន៍លើកឡើងដែរថា ក្នុងនាមជាក្រុមហ៊ុនផែស្ងួតមួយនោះ Bok Seng PPSEZ នឹងខិតខំបំពេញការងាររបស់ខ្លួនឱ្យបានល្អប្រសើរពិសេសផ្តោតលើសេវាកម្មដឹកជញ្ជូន ។ គួរបញ្ជាក់ថា មុននឹងមកចាប់ដៃគូវិនិយោគទុននៅក្នុងប្រទេសកម្ពុជានេះ ក្រុមហ៊ុនផែស្ងួត Bok Seng ធ្លាប់មានបទពិសោធន៍លើផ្នែកវិនិយោគទុននៅប្រទេសសិង្ហបុរីអស់រយៈពេលជាយូរណាស់មកហើយដោយទទួលបានលទ្ធផលយ៉ាងល្អប្រសើរថែមទៀតផង។

លោកចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មក៏បានមានប្រសាសន៍ផងដែរថា ក្នុងនាមក្រសួងពាណិជ្ជកម្ម លោកសង្ឃឹមថា ក្រុមហ៊ុនផែស្ងួតបុកសេងភីភីអេសអ៊ីហ្សេត នឹងក្លាយជាក្រុមហ៊ុនល្បីឈ្មោះមួយនៅក្នុងប្រទេសកម្ពុជា ហើយសំខាន់បំផុតនោះ ក្រុមហ៊ុននេះនឹងអាចក្លាយជាក្រុមហ៊ុនផែស្ងួតគំរូមួយផងដែរសម្រាប់ក្រុមហ៊ុនផែស្ងួតដទៃទៀតយកគំរូតាម ព្រោះអ្វីដែលលោកបានមើលឃើញនៅពេលនេះ គឺក្រុមហ៊ុនមានសមិទ្ធផលនិងសេវាកម្មល្អៗជាច្រើន ។ លោកចមប្រសិទ្ធសង្កត់ធ្ងន់ថា នេះជាលើកទី១ហើយដែលមានផែស្ងួតក្នុងតំបន់សេដ្ឋកិច្ចពិសេស ដោយក្នុងនេះលោកសង្ឃឹមថាគយនឹងធ្វើការឱ្យបានលឿនដើម្បីគិតដល់ផលប្រយោជន៍ជាតិឱ្យបានធំ។[illegible]